# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តប្រើប្រាស់សេវាផ្ទេរប្រាក់ចេញ

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីលើកទឹកចិត្តប្រើប្រាស់សេវាផ្ទេរប្រាក់ចេញ ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ និងដោយបន្ថែមលើការអនុវត្តនៃបញ្ញត្តិ និងលក្ខខណ្ឌគ្រប់គ្រងសេវាធនាគារឌីជីថល បបញ្ញត្តិ និងលក្ខខណ្ឌទូទៅគ្រប់គ្រងគណនី ផលិតផល និងសេវា ព្រមទាំងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធឯទៀត របស់ធនាគារ ព្រីនស៍ អតិថិជនយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម៖

១. រាល់អតិថិជនដែលប្រើប្រាស់សេវាផ្ទេរប្រាក់ចេញតាមប្រព័ន្ធ MoneyGram ជាមួយធនាគារ ព្រីនស៍ ("**អតិថិជន**") អាចចូលរួមក្នុងកម្មវិធីលើកទឹកចិត្តនេះ។

២. អតិថិជនអាចទទួលបានការផ្តល់ជូននូវអត្ថប្រយោជន៍ ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម៖

| ការផ្តល់ជូន | | | | រយៈពេលកម្មវិធី |
|---|---|---|---|---|
| ប្រតិបត្តិការ | បណ្តាញ | កម្រិតកំណត់ប្រចាំថ្ងៃលើ ចំនួនទឹកប្រាក់ផ្ទេរ | កម្រៃសេវាផ្តល់ជូន | ០៣ មិថុនា ២០២៤ ដល់ ០៣ ធ្នូ ២០២៤ |
| ផ្ទេរប្រាក់ចេញតាមប្រព័ន្ធ MoneyGram | សាខាធនាគារព្រីនស៍ | ១០.០០០ ដុល្លារអាមេរិក | ៣ដុល្លារអាមេរិក / ប្រតិបត្តិការ | |
| **សម្គាល់៖**<br>- ការផ្ទេរប្រាក់ចេញពីសាខាធនាគារ ព្រីនស៍ តាមរយៈប្រព័ន្ធ MoneyGram ទៅកាន់បរទេស។<br>- អត្រាប្តូរប្រាក់របស់ប្រព័ន្ធMoneyGram ត្រូវអនុវត្ត។ | | | | |

៣. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអតិថិជន ទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អតិថិជនរូបនោះ នឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ។ អតិថិជនត្រូវប្រគល់មកវិញជូនធនាគារ ព្រីនស៍ នូវរាល់ការផ្តល់ជូនដែលខ្លួនបានទទួលពីធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗ ទៅតាមបញ្ញត្តិច្បាប់ជាធរមាន។ ក្នុងករណីនេះ ធនាគារ ព្រីនស៍ រក្សាសិទ្ធិក្នុងការចាត់វិធានការចាំបាច់ទៅតាមផ្លូវច្បាប់ ចំពោះករណីឆបោក ឬក្លែងបន្លំនេះ។

៤. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អតិថិជន យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អតិថិជន យល់ព្រមដោយមិនអាចដកហូតវិញបានថា អតិថិជនយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់ផលវិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអតិថិជន ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៥. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬការផ្តល់ជូន នៅពេលណាមួយ ក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ ធនាគារ ព្រីនស៍ ដោយជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលមានរបស់ ធនាគារ ព្រីនស៍។

៦. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ ធនាគារ ព្រីនស៍ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។